ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

៣១-០១-២០០៧ -ព្រះរាជក្រម នស/រកម/០១០៧/០០៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ១៦៨៨

៣១-០១-២០០៧ -ព្រះរាជក្រម នស/រកម/០១០៧/០០៦ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ១៦៩៧

២-ព្រះរាជក្រឹត្យ

០៣-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៥១ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនមន្ត្រីចូលនិវត្តន៍ របស់ក្រសួងមហាផ្ទៃ ចំនួន១៤ រូប ដែលបានចូលរួមចំណែកបំពេញភារកិច្ចបំរើជាតិមាតុភូមិ សំរេចបានលទ្ធផលល្អ ១៧០១

០៣-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៥២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ចំនួន០៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ១៧០៣

០៧-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៥៤ ស្តីពីការតែងតាំងឯកឧត្តម **គេខ ស៊ីថា** ជា ឧកញ៉ា ១៧០៤

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០៩-០២-២០០៧ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ១៧០៥

១២-០២-២០០៧ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពីការឈប់ទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ១៧១០

០៨-០២-២០០៧ -អនុក្រឹត្យលេខ ១១៥ អនក្រ.បក ស្តីពីការជូនមេដាយការងារ ១៧១២
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៥៦
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៥៧
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៥៩
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៦០
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការជូនមេដាយសុវត្ថារា ១៧៦១
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការតែងតាំង និង ប្រគល់ភារកិច្ចជូន មន្ត្រីរាជការ ១៧៦៥
០៨-០២-២០០៧ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ១៧៦៦
០៩-០២-២០០៧ -អនុក្រឹត្យលេខ១២៣អនក្រ.បក ស្តីពីការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិ មន្ត្រីរាជការ ១៧៦៧
០៩-០២-២០០៧ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការតែងតាំងមុខងារនាយទាហាន ១៧៧០
១២-០២-២០០៧ -អនុក្រឹត្យលេខ ១២៥ អនក្រ.បក ស្តីពីការតែងតាំងឋានន្តរស័ក្តិនាយនគរបាលជាតិ ១៧៧១
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧២
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១២៧ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧៣
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧៥
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧៦
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧៧
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៧៩
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១៣២ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៨០
១៤-០២-២០០៧ -អនុក្រឹត្យលេខ ១៣៣ អនក្រ.បក ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៧៨១

២.សេចក្តីសំរេច

១៣-០២-២០០៧ -សេចក្តីសំរេចលេខ ០៦សសរ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវនិងចងក្រងប្រវត្តិសកម្មភាព និងសមិទ្ធផលនានានៃកងកម្លាំង នគរបាលជាតិកម្ពុជា ចាប់ពីឆ្នាំ ១៩៤៥ ១៧៨២

III-ការិយាល័យខាងបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៤៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាកឃីត មេនូហ្វេក ឈ័រីង** ១៧៨៤

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៤៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីម ក្មុក ទីង អ៊ិនធើណេសិនណល យូនីធើសីធី** ១៧៨៦

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៥២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថេមប្ ខូ អិលធីឌី** ១៧៨៨

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៥៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេបធីម៉ា ស៊ីល្វសិន** ១៧៩០

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៥៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី ទ៉ាយ ជី ខូ អិលធីឌី** ១៧៩២

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៥៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេខេ & គីអេស ខូ អិលធីឌី** ១៧៩៤

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៦០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង មិច ផ្កាឈូក ភ្លីប** ១៧៩៦

១៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៦១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈិត ឈេង** ១៧៩៨

១៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៦៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) យូថេន សិល អ៊ីមផត អិចផត & ត្រេឌីង** ១៨០០

១៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៦៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គួរឿន គ្រូចេះ អតិថិជន កៅស៊ូ** ១៨០២

១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៦៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.ខេ.ស៊ី.ហូលឌីង** ១៨០៤

១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចី ស៊ី អិន (ខេមបូឌា)** ១៨០៦
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.ជេប អេនជីនារីង** ១៨០៨
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ម៉ានីង ម៉ើលដ៍**
ឡេផេត ១៨១០
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡេវ អ៊ី អ៊ឹមផត អិចផត** ១៨១២
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អារីន** ១៨១៤
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ូស៊ិន អេនជីនា**
រីង ខបភើរេសិន ១៨១៦
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្សូរ៉ា រីលធីឌី** ១៨១៨
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាន ចៀង កំពង់ធំ**
អភិវឌ្ឍន៍ កៅស៊ូ ១៨២០
១៥-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ហ្សូន** ១៨២២
១៦-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **២ អិន គ្រេឌីត** ១៨២៤
១៦-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធារ៉ា កំពង់ធំ អភិ**
វឌ្ឍន៍ កៅស៊ូ ១៨២៦
១៦-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុវណ្ណ ឧត្តរ** ១៨២៨
១៦-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ តា ធូរ** ១៨៣០

ព្រះរាជក្រម

នស/រកម/០១០៧/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៩០/០០១/២០០៧ កបធ.ប ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

2/10

ច្បាប់
ស្តីពី
វិសោធនកម្មច្បាប់ស្តីពីការរៀបចំ
និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រាតែមួយ.–

មាត្រា ១ មាត្រា ៣ ដល់មាត្រា ៥ មាត្រា ១២ មាត្រា ១៤ដល់មាត្រា ១៨ មាត្រា ២២ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ១ .– ថ្មី

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យនិងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ៣ .– ថ្មី

សមាជិកទាំង ៩ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ ឆ្នាំ ។

10

សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ៣ រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយ៣រូប ទៀតត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបាន ។

ក្នុងអាណត្តិទី ១ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួនយ៉ាងច្រើន ៥រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសំឡេងច្រើនជាងគេត្រូវតែងតាំងសម្រាប់ ៩ ឆ្នាំ អ្នកដែលទទួលបានសំឡេងបន្ទាប់ត្រូវតែងតាំងសម្រាប់ ៦ឆ្នាំ និងអ្នកដែលទទួលបានសំឡេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់ ៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួន ២រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសំឡេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូប មានសិទ្ធិគាំទ្របានតែបេក្ខជន ១រូប ប៉ុណ្ណោះ ។

មាត្រា ៤ .- ថ្មី

ក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង សមាជិកចំនួន ៣រូប ត្រូវផ្លាស់ប្តូរនិងតែងតាំងជាថ្មី គឺ ១រូបតែងតាំងដោយព្រះមហាក្សត្រ ១រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់ ៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣រូប ចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវជ្រើសតាំងជាថ្មីបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា ។

អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែស្របតាមលក្ខខណ្ឌ និងរូបមន្តសម្រាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ។

មាត្រា ៥ .– ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែង ត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីតំណែង ឬ មុខរបរទាំងអស់ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលនៅក្នុងមុខតំណែងនិងមុខរបរខាងលើ ឱ្យសុំលាឈប់ពីតំណែង ឬ មុខរបរនោះជាបន្ទាន់ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណាដែលផលប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួនឬការតម្រូវឱ្យដកខ្លួន ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

មាត្រា ១២ .– ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

បទបញ្ញាផ្ទៃក្នុងត្រូវអនុម័តដោយមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

ក្រុមប្រឹក្សាធម្មនុញ្ញមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៤ .- ថ្មី

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬដោយសមាជិកដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើបាន ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកលើសពីពាក់កណ្តាលចូលរួមប្រជុំ ។

មាត្រា ១៥ .- ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។

មាត្រា ១៦ .- ថ្មី

ច្បាប់រៀបចំអង្គការ និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់នោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញមុននឹងត្រូវបានប្រកាសឱ្យប្រើ ។

បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និងវិសោធនកម្មបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា ក្រោយពីព្រឹទ្ធសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យតើបទបញ្ញាផ្ទៃក្នុងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។

បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មបទបញ្ញាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើបទបញ្ញាផ្ទៃក្នុងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។

មាត្រា ១៧ .— ថ្មី

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។

មាត្រា ១៨ .— ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ឬសុំឱ្យបកស្រាយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រ ឬប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

មាត្រា ២២ .— ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះ ត្រូវបន្ថយមកត្រឹម ៨ថ្ងៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍ ។ សមាជិករាយការណ៍ជាសមាជិកនៃក្រុម របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ៣០ថ្មី នៃច្បាប់នេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែកសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាសំឡេងឧត្តមានុភាព ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

7/10

មាត្រា ២៤ .__ ថ្មី

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់ ។

ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី ។

ជំពូកទី ៣
សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

មាត្រា ២៥ .__ ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ២៧ .__ ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេច :

១-លើបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោត ដែលបុគ្គល ឬគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២-លើបណ្ដឹងតវ៉ារបស់បុគ្គល ឬ គណបក្សដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្ដឹងតវ៉ានេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង ។

មាត្រា ២៩ .- ថ្មី

ពាក្យបណ្ដឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តទេ ។ ប៉ុន្តែក្នុងពេលរង់ចាំសេចក្ដីសម្រេចស្ថាពរក្រុមប្រឹក្សាធម្មនុញ្ញ បើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាជាបឋមមួយដើម្បីព្យួរជាបណ្ដោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬសមាជិកព្រឹទ្ធសភាណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលគេប្ដឹងតវ៉ាបាន ។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាពនៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្ដីសម្រេចជាស្ថាពរ ។

មាត្រា ៣០ .- ថ្មី

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ក៏ដូចជាការស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀតជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣ នេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៣៤ -- ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្ដីក្នុងករណីដែលមានការតវ៉ាអំពីនីយតភាពនៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជនដែលប្រកាសថាជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្រប ឬមិនយល់ស្របតាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្ដឹងតវ៉ា ឬប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្ដីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្ដីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅព្រឹទ្ធសភា ឬរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយត្រូវចុះក្នុងរាជកិច្ច ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.០៧០១.០៤៤

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខៈ ៦៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រម

នស/រកម/០១០៧/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ ០៩១/០០២/២០០៧ កបធ.ច ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
វិសោធនកម្មច្បាប់ស្តីពី
ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រាមួយ.-

ត្រូវបានកែប្រែមាត្រា ៣ មាត្រា ៧៣ និងមាត្រា ១២០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ និងមាត្រា ៤៩ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដូចខាងក្រោម :

មាត្រា ៣ .- ថ្មី

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ លើកលែងតែនៅក្នុងស្ថានភាពណាមួយដូចខាងក្រោម :

-ក្នុងករណីប្រធានស័ក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃរំលាយរដ្ឋសភា ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឱ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី ៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៤៩ -- ថ្មី(ពីរ)

សៀវភៅបញ្ជីនេះ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ ហើយត្រូវថតចម្លងផ្លូវការមួយច្បាប់រក្សាទុកនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចសម្រេចកាលបរិច្ឆេទ និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតយ៉ាងយូរដប់ប្រាំ (១៥)ថ្ងៃ ។

ក្នុងករណីដែលរដ្ឋសភា ត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសត្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងពីនេះ ។

មាត្រា ៧៣ -- ថ្មី

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

របៀប បែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ ។

/

៤/៤

មាត្រា១២០ .- ថ្មី

សមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម :

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ។

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេលប្រាំមួយ (៦)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះ តាមលំដាប់លេខរៀង ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

មាត្រា ពីរ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកម.០៧០១.០៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខ: ៧៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ខឹងកេន

៥/៥

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានទទួលការប្រោសប្រទាននូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីចូលនិវត្តន៍ របស់ក្រសួងមហាផ្ទៃ ចំនួន ១៤ រូប ដែលបានចូលរួមចំណែកបំពេញភារកិច្ចបំរើជាតិ មាតុភូមិ សំរេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា

១-លោក សេង ទីឡាត់
២-លោក គង់ ស្រ៊ុន
៣-លោក សាំង ខាន់
៤-លោក ហុង ថ្វើន
៥-លោក ឈួត ភួង
៦-លោក សៀង សង់ឯម
៧-លោកស្រី សោ គិមគួយ

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ អស្សឫទ្ធិ

១-លោក អ៊ុច សុគន្ធ
២-លោក ទួន ឈួង
៣-លោក ប្រាក់ សន់
៤-លោក វ៉ុង ជិន

៥-លោក ពៅ សូត្រ
៦-លោក ម៉ុក ឈួម
៧-លោក កែវ សារិន

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៧០២.០៥៧

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ.ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ ៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៥២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានទទួលការប្រោសប្រទាននូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា

១-លោក **ស្រី សុបិន**
២-លោក **ស៊ុន ហេង**
៣-លោក **នោម ម៉ុនឌន**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ អស្សឫទ្ធិ

១-លោក **អែល សយ**
២-លោក **ប្រាក់ ឡឿន**
៣-លោក **យ៉ិន នូ**
៤-លោក **ភួង សុផាន**

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០២.០៥៨

លេខ ៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ២ ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

យ៉ុន ជំនោន

១/២

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា)

តែងតាំង

ឯកឧត្តម គេង ស៊ីថា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ភល.០៧០២.០៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ: ៥៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ

ថ្ងៃឡង់ដី ស្តីពីកិច្ចសហប្រតិបត្តិការព្រំដែន នៅរាជធានីភ្នំពេញ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខ ធានាសុវត្ថិភាព តាមបណ្តោយព្រំដែន កម្ពុជា-ថៃ ឱ្យបានល្អប្រសើរ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ដែលមានសមាសភាពដូចខាងក្រោម :

១- រដ្ឋមន្ត្រីក្រសួងការពារជាតិ	ជាប្រធាន
២- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ	ជាអនុប្រធាន
៣- រដ្ឋលេខាធិការក្រសួងការពារជាតិ	ជាសមាជិក
៤- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	ជាសមាជិក
៥- អគ្គស្នងការនគរបាលជាតិ	ជាសមាជិក
៦-អគ្គមេបញ្ជាការរង ខភម និងជាមេបញ្ជាការកងទ័ពជើងគោក	ជាសមាជិក
៧- រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ជាសមាជិក
៨- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
៩- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	ជាសមាជិក
១០- រដ្ឋលេខាធិការក្រសួងបរិស្ថាន	ជាសមាជិក
១១- រដ្ឋលេខាធិការក្រសួងទេសចរណ៍	ជាសមាជិក
១២-រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ជាសមាជិក
១៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
១៤- តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន	ជាសមាជិក
១៥- តំណាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន	ជាសមាជិក
១៦- តំណាងអាជ្ញាធរជាតិប្រេងកាត	ជាសមាជិក
១៧-តំណាងទីចាត់ការគយ និងរដ្ឋាករ	ជាសមាជិក
១៨-តំណាងអាជ្ញាធរជាតិគ្រឿងញៀន	ជាសមាជិក
១៩- ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងបាងកក .	ជាសមាជិក
២០- អគ្គលេខាធិការ ក្រសួងការពារជាតិ	ជាសមាជិក
២១-អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា	ជាសមាជិក
២២- អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ	ជាសមាជិក
២៣- អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស	ជាសមាជិក

២៤- នាយរងទី១ សេនាធិការចំរុះ និងជានាយកទីចាត់ការកលយុទ្ធ ជាសមាជិក
២៥- មេបញ្ជាការកងទ័ពជើងទឹក ជាសមាជិក
២៦- មេបញ្ជាការកងទ័ពជើងអាកាស ជាសមាជិក
២៧- នាយក នាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា ជាសមាជិក
២៨- នាយក ទីចាត់ការការងារព្រំដែន ជាសមាជិក
២៩- មេបញ្ជាការកងរាជអាវុធហត្ថ ជាសមាជិក
៣០- នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ ជាសមាជិក

មាត្រា ២ : បង្កើតគណៈកម្មាធិការថ្នាក់យោធភូមិភាគ សំរាប់ដោះស្រាយការងារតាមមូលដ្ឋានរបស់ខ្លួន ដែលមានសមាសភាពដូចខាងក្រោម :

យោធភូមិភាគទី ៤ :

១- មេបញ្ជាការយោធភូមិភាគទី ៤ ជាប្រធាន
២- មេបញ្ជាការរងយោធភូមិភាគទី ៤ ជាអនុប្រធាន
៣- អភិបាលខេត្តព្រះវិហារ ជាអនុប្រធាន
៤- អភិបាលខេត្តឧត្តរមានជ័យ ជាអនុប្រធាន
៥- អភិបាលខេត្តសៀមរាប ជាអនុប្រធាន
៦- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៤ ជាសមាជិក
៧- មេបញ្ជាការតំបន់ប្រតិបត្តិសឹករង ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
៨- ស្នងការនគរបាលខេត្ត ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
៩- ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១០- ប្រធានមន្ទីរសុខាភិបាលខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១១- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១២- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក

យោធភូមិភាគទី ៥

១- មេបញ្ជាការយោធភូមិភាគទី ៥ ជាប្រធាន
២- មេបញ្ជាការរងយោធភូមិភាគទី ៥ ជាអនុប្រធាន
៣- អភិបាលខេត្តបន្ទាយមានជ័យ ជាអនុប្រធាន
៤- អភិបាលខេត្តបាត់ដំបង ជាអនុប្រធាន
៥- អភិបាលខេត្តពោធិសាត់ ជាអនុប្រធាន
៦- អភិបាលក្រុងប៉ៃលិន ជាអនុប្រធាន
៧- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៥ ជាសមាជិក

៨- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

៩- ស្នងការនគរបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១០- ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត បន្ទាយមានជ័យ, បាត់ដំបង, ពោធិសាត់, ប៉ៃលិន ជាសមាជិក

១១- ប្រធានមន្ទីរសុខាភិបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១២- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១៣- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

យោធភូមិភាគទី ៣ :

១- មេបញ្ជាការយោធភូមិភាគទី ៣ ជាប្រធាន

២- មេបញ្ជាការរងយោធភូមិភាគទី ៣ ជាអនុប្រធាន

៣- អភិបាលខេត្តកោះកុង ជាអនុប្រធាន

៤- មេបញ្ជាការមូលដ្ឋានសមុទ្រ (កងទ័ពជើងទឹក) ជាអនុប្រធាន

៥- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៣ ជាសមាជិក

៦- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកោះកុង ជាសមាជិក

៧- ស្នងការនគរបាលខេត្តកោះកុង ជាសមាជិក

៨- ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង ជាសមាជិក

៩- ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង ជាសមាជិក

១០- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង ជាសមាជិក

១១- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្ត កោះកុង ជាសមាជិក

មាត្រា ៣ : គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ត្រូវរៀបចំការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ និងក្រុមការងារតាមច្រកព្រំដែនមួយចំនួន ដែលចាំបាច់ដើម្បីជាជំនួយការដល់គណៈកម្មាធិការនេះ ។ ចំពោះសមាសភាព និងភារកិច្ច អាស្រ័យដោយគណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ជាអ្នកកំណត់ ។

មាត្រា ៤ : គណៈកម្មាធិការនេះមានភារកិច្ច :

-ដឹកនាំ លើកគោលការណ៍សមស្រប ដើម្បីលើកស្ទួយកិច្ចសហប្រតិបត្តិការ រក្សាសន្តិភាពតាមបណ្តោយព្រំដែន និងទំនាក់ទំនងការងារនៃប្រទេសទាំងពីរ កម្ពុជា-ថៃ ឱ្យបានល្អប្រសើរ ។

-ចេញបទបញ្ជា គោលនយោបាយ និងផែនការឱ្យគណៈកម្មាធិការថ្នាក់យោធភូមិភាគ ការិយាល័យទំនាក់ទំនងព្រំដែន និងក្រុមការងារ ដើម្បីអនុវត្ត ។

-ចាត់តាំងគណៈកម្មាធិការឯកទេស ដើម្បីដោះស្រាយរាល់ករណីដែលកើតឡើង ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីមួយៗ ។

មាត្រា ៥ : ទីកន្លែងធ្វើការរបស់គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ស្ថិតក្នុងទីស្តីការក្រសួងការពារជាតិ និងចាត់តាំងក្រុមលេខាធិការមួយដើម្បីធ្វើការងារប្រចាំថ្ងៃ ។

មាត្រា ៦ : គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។

មាត្រា ៧ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពស្ថិតនៅក្នុងមាត្រា ១ - ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការឈប់ទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យ លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ម្រេ ច

មាត្រា ១.-

បញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានឈ្មោះថា **សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ** UNIVERSITY OF TECHNOLOGY PHNOM PENH ហៅកាត់ជាភាសាខ្មែរ "ស.ប.ភ" និងហៅកាត់ជាភាសាអង់គ្លេស "U.T.P.P" ដែលមានទីតាំងស្ថិតនៅអគារលេខ ១៩ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២.-

សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវបញ្ឈប់ការបណ្តុះបណ្តាលគ្រប់កំរិត និងគ្រប់រូបភាព និងត្រូវចេញព្រឹត្តិបត្រពិន្ទុ ដល់និស្សិតទាំងអស់ដែលបានសិក្សានៅសាកលវិទ្យាល័យ តាមកំរិត និងកម្មវិធីសិក្សា ដែលពួកគេបានសិក្សារួចហើយ ។

មាត្រា ៣.-

អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីកសិកម្ម ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១	លោក **ងួន សុធី**	អនុប្រធានការិយាល័យសរុប នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
២	លោក **ឃន ញ៉ី**	អនុប្រធានការិយាល័យសរុប នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
៣	លោក **ណុប ចំរើន**	អនុប្រធានការិយាល័យគណនេយ្យ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
៤	លោក **អ៊ុំ សារី**	អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៥	លោក **ហៃ រស្មី**	អនុប្រធានការិយាល័យចាត់តាំង នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៦	លោក **ថៃ វុទ្ធី**	ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៧	លោកស្រី **សត្យ សារ៉ាង**	អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៨	លោក **ប៊ុន ឡុង**	អនុប្រធានការិយាល័យបៀវត្សពលកម្ម នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៩	លោក **លឹម ជីតង់**	ប្រធានការិយាល័យរដ្ឋបាល នៃអគ្គាធិការដ្ឋាន
១០	លោក **តឹម ហួរ**	ប្រធានការិយាល័យអធិការកិច្ច នៃអគ្គាធិការដ្ឋាន
១១	លោក **ពេជ នៅ**	ប្រធានការិយាល័យតាមដានការអនុវត្ត នៃអគ្គាធិការដ្ឋាន
១២	លោក **គឿន សុជាត**	ប្រធានការិយាល័យទទួលពាក្យបណ្តឹង នៃអគ្គាធិការដ្ឋាន

១៣	លោកស្រី នៅ ស៊ីនថាន	អនុប្រធានការិយាល័យផែនការ នាយកដ្ឋានផែនការ-ស្ថិតិ
១៤	លោកស្រី អ៊ឹម សុខា	មន្ត្រីការិយាល័យផែនការ នាយកដ្ឋានផែនការ-ស្ថិតិ
១៥	លោក ងួន តឹមហៀង	មន្ត្រីការិយាល័យផែនការ នាយកដ្ឋានផែនការ-ស្ថិតិ
១៦	លោកស្រី ផេង សុផាដា	អនុប្រធានការិយាល័យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នាយកដ្ឋានផែនការ-ស្ថិតិ
១៧	លោក ម៉ក់ វិសាល់	មន្ត្រីការិយាល័យ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នាយកដ្ឋានផែនការ-ស្ថិតិ
១៨	លោកស្រី ចាន់ ស៊ីចំណា	អនុប្រធានការិយាល័យទីផ្សារកសិកម្ម នាយកដ្ឋានផែនការ-ស្ថិតិ
១៩	លោក ឡាច ប៊ុនអ៊ីង	ប្រធានការិយាល័យបុគ្គលិក នាយកដ្ឋានកិច្ចការរដ្ឋបាល
២០	លោក តឹម សុវណ្ណា	មន្ត្រីការិយាល័យផ្គត់ផ្គង់ នាយកដ្ឋានកិច្ចការរដ្ឋបាល
២១	លោក ឆេង ឈុនលី	ប្រធានការិយាល័យសន្តិសុខ នាយកដ្ឋានកិច្ចការរដ្ឋបាល
២២	លោក តង់ រដ្ឋា	មន្ត្រីការិយាល័យរដ្ឋបាល នាយកដ្ឋានកិច្ចការរដ្ឋបាល
២៣	លោកស្រី តាន់ សិទ្ធី	មន្ត្រីការិយាល័យរដ្ឋបាល នាយកដ្ឋានកិច្ចការរដ្ឋបាល
២៤	លោក ស្រី សែត	មន្ត្រីការិយាល័យសន្តិសុខ នាយកដ្ឋានកិច្ចការរដ្ឋបាល
២៥	លោក ម៉ៅ វុធ	មន្ត្រីការិយាល័យផ្គត់ផ្គង់ នាយកដ្ឋានកិច្ចការរដ្ឋបាល
២៦	លោក យិន ឌី	ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
២៧	លោក ស៊ីវ ទូច	ប្រធានការិយាល័យផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
២៨	លោក រាជ សម្បត្តិ	អនុប្រធានការិយាល័យផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
២៩	លោក ស៊ុន ទ្រី	អនុប្រធានការិយាល័យប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ច នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៣០	លោក ហ៊ាន វណ្ណបាន	អនុប្រធាននាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣១	លោក ងិន នាយ	អនុប្រធាននាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣២	លោក ហូ ពុទ្ធា	ប្រធានការិយាល័យគ្រប់គ្រងជីជាតិកែលំអដីកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ
៣៣	លោក ខាន់ សំបាន	ប្រធានការិយាល័យកំណត់តំបន់ដាំដុះ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៤	អ្នកស្រី យស់ សាងកានី	ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៥	លោក ទី សុង	ប្រធានការិយាល័យផែនការ-គណនេយ្យ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៦	លោក សៅ ចេស្តា	អនុប្រធានការិយាល័យគ្រប់គ្រងពូជដំណាំ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៧	លោក តាត សាយ	អនុប្រធានការិយាល័យផែនការ-គណនេយ្យ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៨	លោក ឌី សំអាន	អនុប្រធានការិយាល័យការពារដំណាំ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៣៩	លោក ប៊ុន ទូនស៊ីម៉ូណា	អនុប្រធានការិយាល័យការពារដំណាំ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤០	លោក ហេង ឈុនហ៊ី	អនុប្រធានការិយាល័យការពារដំណាំ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤១	អ្នកស្រី អឿ ឡាំងហ៊ុន	អនុប្រធានការិយាល័យគ្រប់គ្រងជីជាតិដី នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤២	លោក អំ ភិរម្យ	អនុប្រធានការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤៣	លោក អឿន ពិសិដ្ឋ	អនុប្រធានការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤៤	លោក នុត សុខុម	ប្រធានស្ថានីយ៍ក្បាលកោះ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤៥	លោក ម៉េង លាភ	អនុប្រធានកសិដ្ឋានទួលសំរោង នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
៤៦	លោក សួន វុធ	អគ្គនាយករង អគ្គនាយកដ្ឋានចំការកៅស៊ូ
៤៧	លោក អៀម សារិទ្ធ	អនុប្រធានការិយាល័យសំណង់ឧស្សាហកម្ម អគ្គនាយកដ្ឋានចំការកៅស៊ូ
៤៨	លោក យា ស្រ៊ា	អនុប្រធានការិយាល័យផែនការគណនេយ្យ អគ្គនាយកដ្ឋានចំការកៅស៊ូ
៤៩	លោក ញ៉ែប សឿន	អនុប្រធានការិយាល័យសរុប‘អគ្គនាយកដ្ឋានចំការកៅស៊ូ
៥០	លោក នុត តារា	មន្ត្រីការិយាល័យរដ្ឋបាល អគ្គនាយកដ្ឋានចំការកៅស៊ូ
៥១	លោក ម៉េង សុខុន	ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប

៥២	លោក **ស៊ុន សាម៉ន**	អនុប្រធានការិយាល័យសិក្សា សាលាជាតិកសិកម្មព្រែកលៀប
៥៣	លោក **ចាន់ បូរី**	ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ សាលាជាតិកសិកម្មព្រែកលៀប
៥៤	លោក **ជុន ចាន់សុផល**	ប្រធានមន្ទីរពិសោធន៍ សាលាជាតិកសិកម្មព្រែកលៀប
៥៥	លោក **ភាំ វេងហេង**	ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសេដ្ឋកិច្ចកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប
៥៦	លោក **ហង់ ប៊ុនណារ៉ា**	ប្រធានដេប៉ាតឺម៉ង់សាក់វប្បកម្ម សាលាជាតិកសិកម្មព្រែកលៀប
៥៧	លោក **ចាន់ វុតធី**	អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក សាលាជាតិកសិកម្មព្រែកលៀប
៥៨	លោក **ជ័យ មន្ថា**	ប្រធានដេប៉ាតឺម៉ង់កសិ-ឧស្សាហកម្ម សាលាជាតិកសិកម្មព្រែកលៀប
៥៩	លោក **សុខ សុផល**	អនុប្រធានមជ្ឈមណ្ឌលឯកសារ សាលាជាតិកសិកម្មព្រែកលៀប
៦០	លោក **នែម ថា**	អនុប្រធានផ្នែកបណ្តុះបណ្តាលបន្ត សាលាជាតិកសិកម្មព្រែកលៀប
៦១	លោក **សុង ប្រុស**	អនុប្រធានផ្នែកបណ្តុះបណ្តាលបន្ត សាលាជាតិកសិកម្មព្រែកលៀប
៦២	លោក **លាង អ្នខេង**	ប្រធានដេប៉ាតឺម៉ង់ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទ សាលាជាតិកសិកម្មព្រែកលៀប
៦៣	លោក **ប៊ុច ប៊ុនណា**	អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
៦៤	លោក **លី សុវុទ្ធី**	មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង
៦៥	លោក **អ៊ុ កន្និដ្ឋា**	មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង
៦៦	លោក **អ៊ុំ សុគន្ធ**	អនុប្រធានស្នាក់ការអធិការកិច្ចនេសាទសមុទ្រ នាយកដ្ឋានជលផល
៦៧	លោក **គីម សុគន្ធ**	មន្ត្រីការិយាល័យវិវាទ នាយកដ្ឋានជលផល
៦៨	លោក **ខេស ហ៊ីម**	អនុប្រធានស្ថានីយ៍ស្រាវជ្រាវជលផល នាយកដ្ឋានជលផល
៦៩	លោក **ប៉ែន សារ៉េន**	អនុប្រធានស្ថានីយ៍ស្រាវជ្រាវជលផល នាយកដ្ឋានជលផល
៧០	លោក ងួន គីមឈេន	អនុប្រធានស្ថានីយ៍ស្រាវជ្រាវជលផល នាយកដ្ឋានជលផល
៧១	លោក ធ សែនសេរីវឌ្ឍន៍	ប្រធានការិយាល័យគុណភាព និង កែច្នៃ នាយកដ្ឋានជលផល
៧២	លោក សុង ហុង	ប្រធានស្នាក់ការអធិការកិច្ចនេសាទចតុមុខ នាយកដ្ឋានជលផល
៧៣	លោក ស៊ុន ធី	ប្រធានស្នាក់ការអធិការកិច្ចនេសាទមេគង្គ នាយកដ្ឋានជលផល
៧៤	លោក ទឹម សារ៉ាត់	ប្រធានស្នាក់ការអធិការកិច្ចនេសាទបឹងទន្លេសាប នាយកដ្ឋានជលផល
៧៥	លោក ញ៉ែម អុន	អនុប្រធានស្នាក់ការអធិការកិច្ចនេសាទបឹងទន្លេសាប នាយកដ្ឋានជលផល
៧៦	លោក ព្រំ ស៊ីថា	អនុប្រធានការិយាល័យកិច្ចការដែននេសាទ និងផ្សព្វផ្សាយ នាយកដ្ឋានជលផល
៧៧	លោកស្រី រុន សុវណ្ណដារី	អនុប្រធានការិយាល័យផែនការគណនេយ្យ នាយកដ្ឋានជលផល
៧៨	លោកស្រី ឌុច សុធារី	មន្ត្រីការិយាល័យផែនការគណនេយ្យ នាយកដ្ឋានជលផល
៧៩	លោក សេង ស៊ុនណារុន	អនុប្រធានការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨០	លោក ជា សុខុន	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨១	លោក លី ស៊ិន	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨២	លោក មាន ភិរុណ	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨៣	អ្នកស្រី ចាន់ ភារីយា	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨៤	អ្នកស្រី ភាំ ផារី	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨៥	អ្នកស្រី អ៊ុង សុខាល័យ	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨៦	អ្នកស្រី ជា សុម៉ាលី	មន្ត្រីការិយាល័យរដ្ឋបាល និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលព្រៃឈើ
៨៧	លោក សួន សុវណ្ណ	ប្រធានការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៨៨	លោក សូ លន	អនុប្រធានការិយាល័យអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្មឈើ រដ្ឋបាលព្រៃឈើ
៨៩	លោក នង ឱវ៉ាន់	អនុប្រធានការិយាល័យអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្មឈើ រដ្ឋបាលព្រៃឈើ
៩០	លោក រស់ កណ្ណារ៉ា	អនុប្រធានការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ

៩១	លោក ផង តុល	អនុប្រធានការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩២	អ្នកស្រី ចេង លក្ខិណា	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៣	អ្នកស្រី ប៉ែន ឡៃយីង	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៤	អ្នកស្រី ឃី សុផាន់ណា	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៥	លោក ផ្លុង សារ៉ាន	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៦	លោក ថេត ប៊ុនសុង	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៧	លោក ជា ស្រ៊ាន	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៨	អ្នកស្រី តឹម ភ័ន់នី	មន្ត្រីការិយាល័យនីតិកម្ម-វិវាទ រដ្ឋបាលព្រៃឈើ
៩៩	លោក ទៀង សុខុម	អនុប្រធានការិយាល័យគ្រប់គ្រងទីជំរាល និងដីព្រៃឈើ រដ្ឋបាលព្រៃឈើ
១០០	លោក ប៉ក់ ជាលី	អនុប្រធានការិយាល័យគ្រប់គ្រងទីជំរាល និងដីព្រៃឈើ រដ្ឋបាលព្រៃឈើ
១០១	លោក ហែម សារ៉ាវុធ	មន្ត្រីការិយាល័យគ្រប់គ្រងទីជំរាល និងដីព្រៃឈើ រដ្ឋបាលព្រៃឈើ
១០២	លោក ឈាង ដានី	អនុប្រធានការិយាល័យការពារសត្វព្រៃ រដ្ឋបាលព្រៃឈើ
១០៣	លោក ពិន លីវ៉ុន	អនុប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ រដ្ឋបាលព្រៃឈើ
១០៤	លោក ញឹម ធី	អនុប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌល សង្គ្រោះសត្វព្រៃភ្នំតាម៉ៅ រដ្ឋបាលព្រៃឈើ
១០៥	អ្នកស្រី ក្វាន់ សារុន	មន្ត្រីឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ រដ្ឋបាលព្រៃឈើ
១០៦	លោក អៀ វណ្ណា	អនុប្រធានការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១០៧	លោកស្រី គិវ លក្ខិណា	អនុប្រធានការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១០៨	លោក សុក កាណេត	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១០៩	អ្នកស្រី នាង បូនុម	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១០	អ្នកស្រី យ៉ង់ សុជាតា	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១១	អ្នកស្រី ឈិន សំអាង	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១២	អ្នកស្រី វណ្ណ ម៉ាលី	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១៣	អ្នកស្រី អ៊ឹម ស៊ីនឿន	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១៤	អ្នកស្រី ធាន ប៊ុនសូលក្ខណា	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១៥	អ្នកស្រី ងិន មករា	មន្ត្រីការិយាល័យផែនការ និងគណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើ
១១៦	លោក គិត ប៊ុណ្ណា	អនុប្រធានការិយាល័យកិច្ចការព្រៃឈើ រដ្ឋបាលព្រៃឈើ
១១៧	លោកស្រី ប្រាជ្ញ ច័ន្ទម៉ាលី	មន្ត្រីការិយាល័យកិច្ចការព្រៃឈើ រដ្ឋបាលព្រៃឈើ
១១៨	លោក ប៊ូរី ពិសិដ្ឋ	មន្ត្រីការិយាល័យកិច្ចការព្រៃឈើ រដ្ឋបាលព្រៃឈើ
១១៩	អ្នកស្រី កែវ រតនា	មន្ត្រីការិយាល័យកិច្ចការព្រៃឈើ រដ្ឋបាលព្រៃឈើ
១២០	លោក បិ សុវណ្ណយ៉ែន	មន្ត្រីការិយាល័យកិច្ចការព្រៃឈើ រដ្ឋបាលព្រៃឈើ
១២១	លោក នុព សុធា	អនុប្រធានការិយាល័យផ្សព្វផ្សាយព្រៃឈើ រដ្ឋបាលព្រៃឈើ
១២២	លោក គីមហ៊ាន ច័ន្ទសុភត្រា	អនុប្រធានការិយាល័យផ្សព្វផ្សាយព្រៃឈើ រដ្ឋបាលព្រៃឈើ
១២៣	លោក ព្រាប សំ	អនុប្រធានការិយាល័យដាំឈើ រដ្ឋបាលព្រៃឈើ
១២៤	លោក អួន សំអុល	អនុប្រធានការិយាល័យដាំឈើ រដ្ឋបាលព្រៃឈើ
១២៥	លោក សូ ចន	នាយរង អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប
១២៦	លោក ស៊ូ សោគន្ធ	នាយរងខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ
១២៧	លោក តាន់ សេដ្ឋា	នាយផ្នែករដ្ឋបាលព្រៃឈើដាំក្សាន្ត
១២៨	លោក ឡុង ប៊ុង	នាយរង អធិការដ្ឋានរដ្ឋបាលព្រៃឈើ ឈូងសមុទ្រ
១២៩	លោក ងន ប៊ុនធឿន	មន្ត្រីអធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រ

